ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល លេខ 701 ថ្ងៃ 05.08.22 9h20

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិកាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

ចូល លេខ 1314 ថ្ងៃ 15.8.22

**កម្មវត្ថុ:** របាយការណ៍នៃកិច្ចប្រជុំស្តីពីកិច្ចប្រជុំជាមួយ ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ពាក់ព័ន្ធការងារប្រឆាំងអំពើជួញដូរមនុស្ស កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។

**យោង:** - លិខិតលេខ៥៣៤៤ កបទ.សអ.អមរ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២។

- ចំណារឯកភាពភាពរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធានគណៈកម្មាធិកាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះថ្ងៃទី១៥ ខែកក្កដាឆ្នាំ២០២២។

សេចក្តីដូចបានគោរពជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពអនុញ្ញាតរាយការណ៍ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ នៅទីស្តីការក្រសួងកិច្ចការនារី នាងខ្ញុំបានដឹកនាំកិច្ចប្រជុំ ជាមួយឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធការងារប្រឆាំងអំពើជួញដូរមនុស្ស ដែលមានខ្លឹមសារ ដូចខាងក្រោម÷

**ក.សមាសភាពអ្នកចូលរួម**

- **ភាគីកម្ពុជា:** នាងខ្ញុំ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃ គ.ជ.ប.ជ លោកជំទាវ **ជូ ប៊ុនអេង** លោកជំទាវ **ញាណ សុចិត្រា** អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម លោក **ស៊ុំ វណ្ណារ័ត្ន** ប្រធានការិយាល័យផ្នែកច្បាប់ និងលោក **នោ បណ្ឌូល** អនុប្រធានការិយាល័យទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ នៃក្រសួងកិច្ចការនារី។
- **ភាគីសហរដ្ឋអាមេរិក:** ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក Jonathan Adam នាយកការិយាល័យនយោបាយអមស្ថានទូតអាមេរិកនិងលោក **ទូត បញ្ញារ៉ា** អ្នកបកប្រែអមស្ថានទូតអាមេរិក

**ខ.ដំណើរនៃកិច្ចប្រជុំ**

ជាកិច្ចចាប់ផ្តើម **នាងខ្ញុំ** បានថ្លែងមតិស្វាគមន៍ចំពោះវត្តមាន **ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក** និងសហការី ក្នុងជំនួបពិភាក្សាការងារពាក់ព័ន្ធនឹងការប្រឆាំងអំពើជួញដូរមនុស្សបន្ទាប់ពីការចេញផ្សាយរបាយការណ៍ឃ្លាំមើលរបស់សហរដ្ឋអាមេរិក កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ចំពោះចំណាត់ថ្នាក់លេខ៣នៃប្រទេសកម្ពុជា ទោះបីកម្ពុជាបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដោយសហការយ៉ាងទូលំទូលាយជាមួយសហរដ្ឋអាមេរិចក៏ដោយ ហើយទទួលបានលទ្ធ

ផលប៉ះពាល់អវិជ្ជមានដែលភាគីកម្ពុជាសុំសួរទៅសហរដ្ឋអាមេរិចវិញថា តើកម្ពុជាមានចំណុចខ្វះខាតណាទៀតដែលត្រូវបំពេញបន្ថែមលើអនុសាសន៍ ចេញក្នុងរបាយការណ៍ឃ្លាំមើល? ដោយសង្កេតឃើញថាអនុសាសន៍ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ មានខ្លឹមសារស្រដៀងគ្នាលើកលែងតែអនុសាសន៍ទី៦ថ្មី ក្នុងចំណោមអនុសាសន៍ទាំងអស់ក្នុងរបាយការណ៍ឆ្នាំ២០២២ ដែលចែងលើការឆបោកតាមប្រព័ន្ធអនឡាញ (Online Scam)។ នាងខ្ញុំបានជូន លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានមតិយោបល់ព្រមទាំងបង្ហាញនូវវឌ្ឍនភាពការងារដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាលនិងលោកជំទាវបានស្នើសុំផងដែរឱ្យភាគីសហរដ្ឋអាមេរិកបញ្ជាក់ឡើងវិញនូវចំណុចដែលខ្វះខាតថាកម្ពុជា ត្រូវបំពេញបន្ថែមលើរបាយការណ៍ **គ.ជ.ប.ជ ប្រចាំឆ្នាំ២០២១** ។

**ភាគីសហរដ្ឋអាមេរិក**: ជាកិច្ចបន្ត ឯកឧត្តម **W. Patrick Murphy** បានទទួលស្គាល់និងកោតសរសើរនៅលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក៏ប៉ុន្តែអនុសាសន៍ ក្នុងរបាយការណ៍ឃ្លាំមើល ឆ្នាំ២០២១ មិនទាន់ទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុកនៅឡើយ។ មានទិន្នន័យមិនគ្រប់គ្រាន់ រឺមិនឆ្លើយតបទៅនឹងបញ្ហាដើម្បីបង្ហាញ និងគាំទ្រទៅលើវឌ្ឍនភាពការងារនៅក្នុងរបាយការណ៍របស់**គ.ជ.ប.ជ**។ ទោះបីយ៉ាងណា **ឯកឧត្តមឯកអគ្គរដ្ឋទូត** នៅតែស្នូមឱ្យ **គ.ជ.ប.ជ** បន្តសហប្រតិបត្តិការជាមួយសហរដ្ឋអាមេរិច ក្នុងគោលបំណងបង្កើនថែមទៀតប្រសិទ្ធិភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏បានលើកយកចំណុចវឌ្ឍនភាពលើការងារមួយចំនួនក្នុងប្រទេសកម្ពុជាពាក់ព័ន្ធទៅនឹងការកើនឡើងនូវចំនួនការចាប់ខ្លួន ការបញ្ជូនទៅតុលាការ ការកាត់ទោស ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការធ្វើមាតុភូមិនិវត្តន៍ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបញ្ជាក់ថាការវាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់ឱ្យកម្ពុជាក្នុងរបាយការណ៍ឃ្លាំមើលឆ្នាំ២០២២ ផ្អែកទៅលើលទ្ធផលនៃសកម្មភាពជាក់ស្តែង មិនពាក់ព័ន្ធនិងបញ្ហានយោបាយទេ ហើយបានលើកឧទាហរណ៍ថាសម្ព័ន្ធមិត្តសហរដ្ឋអាមេរិចមួយចំនួនក៏មានស្ថិតនៅក្នុងចំណាត់ថ្នាក់ទី៣ដែរ។តទៅទៀត**ឯកឧត្តមទូត**បានលើកចំណុចពាក់ព័ន្ធមួយចំនួនទៀតដែល **គ.ជ.ប.ជ** ត្រូវផ្តោតការយកចិត្តទុកដាក់មានជាអាទិ៍÷

- ស្នើសុំថ្នាក់ដឹកនាំ និងមន្ត្រីបន្តប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរដែលជាឧក្រិដ្ឋកម្មឆ្លងដែនដ៏អាក្រក់មួយដែលគ្រប់ប្រទេសត្រូវចូលរួមទប់ស្កាត់ទាំងអស់គ្នាក្នុងតំបន់ និងពិភពលោក។ មិនគួរពុះពារអនុវត្តសកម្មភាពដើម្បីតែចំណាត់ថ្នាក់ល្អក្នុងរបាយការឃ្លាំមើលនោះទេ។
- ការចែករំលែកព័ត៌មានមិនបានធ្វើឱ្យទូលំទូលាយជាពិសេសផ្នែកព័ត៌មាននគរបាល ដែលពាក់ព័ន្ធនឹងទិន្នន័យលើចំនួននៃការចាប់ខ្លួនជនល្មើស និងមន្ត្រីពាក់ព័ន្ធ។ **ឯកឧត្តមទូត** បានធ្វើការកោតសរសើរទៅលើ២ករណីគឺ÷ ករណីចាប់ខ្លួនអធិការនគរបាលស្រុកកំរៀង និងមន្ត្រីយោធាថ្នាក់ឧត្តមសេនីយ៍ទោ១រូប ។
- ភាគីសហរដ្ឋអាមេរិចស្នើសុំក្រសួងយុត្តិធម៌ រៀបចំទម្រង់ទិន្នន័យកុំឱ្យខុសគ្នាពីមួយឆ្នាំទៅមួយឆ្នាំ និងផ្តល់ទិន្នន័យលម្អិតដែលមាន មានសង្គតិភាព អាចវិភាគ និងប្រៀបធៀបបានពី១ឆ្នាំទៅ១ឆ្នាំ។
- បង្កើនការធ្វើអធិការកិច្ចដោយមិនមានការជូនដំណឹងជាមុន នៅសិប្បកម្មឡឥដ្ឋជាដើម ក្នុងករណីដែលមានការជួញដូរកម្លាំងពលកម្ម ត្រូវបញ្ជូនម្ចាស់អាជីវកម្មទៅទទួលខុសត្រូវចំពោះមុខច្បាប់។
- ជាសរុបគួរផ្តោតការយកចិត្តទុកដាក់ទៅលើអនុសាសន៍ទី១ ទី២ ទី៣ ទី៥ និងទី៦ នៃរបាយការណ៍ឃ្លាំមើលឆ្នាំ២០២២។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានអនុញ្ញាតឱ្យលោក Jonathan Adam មានប្រសាសន៍បន្ថែមនៅលើចំណុចខ្វះខាតដែលមានខ្លឹមសារដូចតទៅ៖

- មូលដ្ឋាននៃទិន្នន័យ (Data) ឱ្យមានភាព ច្បាស់លាស់ ឆ្លើយតប និងអាចយកទៅវិភាគបាន។
- ស្នើសុំ គ.ជ.ប.ជ មេត្តាផ្តោតការយកចិត្តទុកដាក់លើផែនការសកម្មភាពជាតិ ដែលឆ្លើយតបទៅនិងអនុសាសន៍ទាំង១៦ ចែងក្នុងរបាយការណ៍ឃ្លាំមើលឆ្នាំ២០២២ ជាពិសេសការពង្រឹងបន្ថែមទៀតការអនុវត្តច្បាប់ បង្កើនការចុះធ្វើអធិការកិច្ច ដោយមិនប្រាប់ជាមុន និងការផ្តល់ទិន្នន័យនៅលើកញ្ចប់ថវិកាជាតិដែលទ្រទ្រង់ ផែនការសកម្មភាពជាតិទប់ស្កាត់ការជួញដូរមនុស្ស។
- ពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ។
- ទប់ស្កាត់ការបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ (Online Scam) ដែលជារូបមន្តថ្មីនៃការជួញដូរក្នុងយុគសម័យឌីជីថល ។

នាងខ្ញុំបានថ្លែងអំណរគុណ ភាគីអាមេរិចដែលបានផ្តល់ព័ត៌មានលើកឡើងរបស់ខ្លួនហើយ សង្ឃឹមថាជំនួបនេះ និងអនុញ្ញាតឱ្យកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរអាចមានដំណើរការបន្តទៅមុខប្រកបដោយការយោគយល់គ្នា។ នាងខ្ញុំក៏បានបញ្ជាក់បន្ថែមលើឆន្ទៈនយោបាយដ៏មោះមុត របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងការដឹកនាំការងារប្រកបដោយការប្តេជ្ញាចិត្តដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា **ប្រធានគ.ជ.ប.ជ** ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏ទទួលស្គាល់ផងដែរនៅលើការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំកម្ពុជា។

**គ.មុននិងបញ្ចប់**: ដើម្បីឆ្លើយតបទៅនឹងគោលបំណងដើមរបស់ភាគីសហរដ្ឋអាមេរិចក្នុងការសុំឱ្យមានជំនួបថ្ងៃនោះ ចំពោះសំណួរដែលសួរថា តើមានយុទ្ធសាស្ត្រថ្មីអ្វីទៀតដែលភាគីទាំងពីរអាចយកមកអនុវត្តនាពេលអនាគត ដើម្បីបង្កើនប្រសិទ្ធភាពការងារថែមទៀត? **នាងខ្ញុំ**បានឆ្លើយតបថា ត្រូវរង់ចាំកិច្ចប្រជុំ **គ.ជ.ប.ជ** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា **ប្រធានគ.ជ.ប.ជ** ដើម្បីបញ្ជាក់នៅលើយុទ្ធសាស្ត្រថ្មី និងរូបមន្តនៃកិច្ចសហប្រតិបត្តិការថ្មីរវាងភាគីទាំងពីរ។ ភាគីទាំងពីរក៏បានឯកភាពឱ្យមានកិច្ចប្រជុំក្រុមការងារថ្នាក់បច្ចេកទេសក្រោយកិច្ចប្រជុំ **គ.ជ.ប.ជ** ដើម្បីទទួលយកធាតុចូល និងកំណត់ទិសដៅការងារបន្ត ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** និងជា**ប្រធាន គ.ជ.ប.ជ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃ ពុធ ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**អនុប្រធាន និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃ គ.ជ.ប.ជ**

កិត្តិបណ្ឌិត អ៊ីង កន្ថាផាវី